# ការប្រឡងតាមជំពូក

## ការណែនាំ

នៅពេលដែលអ្នកបានបញ្ចប់ការសិក្សារបស់អ្នកទៅតាមជំពូកនីមួយៗហើយ ចូរឆ្លើយសំណួរប្រឡងតាមជំពូក ដោយប្រើប្រាស់ក្រដាសចម្លើយទៅតាមលំហាត់ប្រឡងជំពូកនីមួយៗ ដើម្បីកត់ត្រាចម្លើយរបស់អ្នក។

សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយតែមួយគត់ដែលល្អជាងគេសម្រាប់សំណួរនីមួយៗ។ ចូរផាត់ពណ៌ខ្មៅទៅលើប្រឡោះចម្លើយដែលអ្នកជ្រើសរើស។ *ត្រូវតែប្រាកដថាលេខនៅក្នុងក្រដាសចម្លើយដូចទៅនឹងលេខនៅក្នុងសំណួរដែលអ្នកឆ្លើយ។*

## ឧទាហរណ៍

១ ការកើតជាថ្មីគឺមានន័យថា

ក) មានអាយុតិច

ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ

គ) ចាំផ្តើមឆ្នាំថ្មី

ឃ) ស្វែងរកក្រុមជំនុំផ្សេងមួយទៀត

ចម្លើយដែលត្រឹមត្រូវគឺ **ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ** ដូច្នេះអ្នកត្រូវផាត់ពណ៌ខ្មៅនៅក្នុងចន្លោះអក្សរ ខ យ៉ាងដូច្នេះ៖

១ (ក) ● (គ) (ឃ)

## ការប្រគល់ ចម្លើយការប្រឡង

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ និង បានឆ្លើយសំណួរការប្រឡងទាំងអស់ហើយ សូមផ្ញើក្រដាសចម្លើយរបស់អ្នកទៅឲ្យគ្រូ ឬ ការិយាល័យដែលនៅក្នុងតំបន់របស់អ្នកដើម្បីធ្វើការកែសម្រួល។

# ការប្រឡងជំពូកទីមួយ

១ យោងតាមគម្ពីរលោកុប្បត្តិ ៣:១៦-១៩ ទុក្ខលំបាករបស់មនុស្ស និង គ្រោះធម្មជាតិកើតមានឡើងដោយសារ
- ក) ព្រះជាម្ចាស់ព្រះពិរោធជាមួយនឹងសាតាំង។
- ខ) ព្រះជាម្ចាស់ព្រះពិរោធជាមួយនឹងលោកអដាំ និង នាងអេវ៉ា
- គ) បណ្តាសារដែលជាលទ្ធផលនៃអំពើបាប។
- ឃ) កំហឹង និង គំនុំរបស់សាតាំងទៅចំពោះព្រះជាម្ចាស់។

២ ចាប់តាំងពីពេលដែលលោកអដាំ និង នាងអេវ៉ាមិនស្តាប់បង្គាប់ព្រះជាម្ចាស់មក មនុស្សគ្រប់គ្នាបានកើតមកជាមួយនឹង
- ក) សមត្ថភាពដើម្បីច្រានចោលអំពើបាប និងរស់នៅក្នុងជីវិតមួយដ៏ល្អឥតខ្ចោះ។
- ខ) ចិត្តបរិសុទ្ធដែលធ្វើឲ្យយើងមានលក្ខណៈមួយដែលគ្មានបាបសោះឡើយ។
- គ) គ្មានអំណាចអ្វីដើម្បីនឹងប្រឆាំងជាមួយនឹងការល្បួងឲ្យប្រព្រឹត្តអំពើបាបបានសោះ។
- ឃ) និស្ស័យបាបដែលជំរុញឲ្យជ្រើសរើសប្រព្រឹត្តអំពើបាប។

៣ យើងមានទំនួលខុសត្រូវចំពោះអំពើបាបរបស់យើងដោយខ្លួនឯង ព្រោះយើង
- ក) គ្មានអំណាចក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយ នឹងតែងតែជ្រើសយកអំពើបាប។
- ខ) គួរឲ្យទុកចិត្តបាន ក្នុងការសម្រេចចិត្តថាធ្វើអំពើល្អ ឬ ធ្វើអំពើអាក្រក់។
- គ) អាចខិតខំធ្វើការយ៉ាងលំបាកជាមួយវាបាន និង រស់នៅជីវិតដែលគ្មានបាបសោះ។
- ឃ) មិនស្មោះត្រង់ ក្នុងការសារភាពនៅពេលដែលយើងបានប្រព្រឹត្តអំពើបាប។

៤ យោងទៅតាមគម្ពីរ ១ពេត្រុស ១:៦-៧ ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យមានបញ្ហា និង ទុក្ខព្រួយកើតមាននៅក្នុងជីវិតរបស់យើង?
- ក) ដើម្បីដាក់ទោសយើងសម្រាប់អាកប្បកិរិយាមានបាប ឬ សម្រាប់ជំនឿខ្សោយ។
- ខ) ដើម្បីធ្វើឲ្យយើងកោតខ្លាចទ្រង់ និង ឫទ្ធានុភាពរបស់ទ្រង់ផង។
- គ) ដើម្បីបន្សុទ្ធ និង ពង្រឹងជំនឿរបស់យើងឲ្យរឹងមាំ។
- ឃ) ដើម្បីបន្ថែមក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើង។

៥ គម្ពីររ៉ូម៨:១៧ បានចែងថាហេតុផលមួយដែលព្រះជាម្ចាស់អនុញ្ញាតឲ្យយើងរងទុក្ខ គឺដើម្បីបើកបង្ហាញ
- ក) ភាពទន់ខ្សោយរបស់យើង។
- ខ) សិរីរុងរឿងរបស់ព្រះគ្រិស្តនៅក្នុងយើង។
- គ) សម្រាប់អស់អ្នកដែលស័ក្តិសមទទួលការសង្គ្រោះ។
- ឃ) ឫទ្ធានុភាពរបស់ទ្រង់ដើម្បីដាក់ទោសយើងសម្រាប់អំពើបាបរបស់យើង។

៦ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការល្បងលយើងគឺដើម្បីធ្វើឲ្យយើង
ក) បរាជ័យ។
ខ) ព្រួយបារម្ភ។
គ) រងទុក្ខ។
ឃ) ខិតខំព្យាយាម។
៧ បញ្ហាសំខាន់ជាងគេបំផុតដែលខ្ញុំនឹងត្រូវប្រឈមមុខជាមួយនៅក្នុងជីវិតរបស់ខ្ញុំគឺ
ក) ភាពអាត្មានិយមរបស់ខ្ញុំ។
ខ) បញ្ហាអំពើបាបរបស់ខ្ញុំ។
គ) ចំណង់ផ្លូវភេទរបស់ខ្ញុំ។
ឃ) ការខ្វះការទប់ចិត្តខ្លួនឯង។
៨ យោងតាមសេចក្ដីបង្រៀនរបស់ព្រះយេស៊ូនៅលើភ្នំ ក្រឹត្យវិន័យទាំងដប់ប្រការ
ក) លែងត្រូវការការគោរពប្រណិបត្តិតាមទៀតហើយ។
ខ) មិនអាចមានអ្នកគោរពតាមបានឡើយតាំងពីដើមរៀងមក។
គ) អាចនឹងគោរពតាមបាន តាមរយៈការទុកចិត្តលើព្រះគ្រិស្ដ។
ឃ) គឺជាមគ្គទេសក៏តាំងពីដើមរៀងមក មិនមែនជាក្រឹត្យវិន័យនោះទេ។
៩ ក្រឹត្យវិន័យទាំងដប់ប្រការ ទាក់ទងទៅនឹងអ្វីដែលយើងធ្វើ ហើយសុភមង្គលពិតរបស់ព្រះគ្រិស្ដ ទាក់ទងទៅនឹងអ្វី
ក) ដែលគួរតែជាយើង។
ខ) ដែលយើងមាន។
គ) ដែលយើងចង់បាន។
ឃ) ដែលយើងជឿ។
១០ ចូរអានគម្ពីរម៉ាកុស ១២:២៨-៣១ ។ តើអ្វី ជាគ្រឹះមូលដ្ឋាននៃក្រឹត្យវិន័យដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់យើង?
ក) ក្ដីស្រឡាញ់
ខ) ជំនឿ
គ) បំណងចិត្ត
ឃ) ព្រះពរ
១១ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើង តាមរយៈបទគម្ពីរ ហើយយើងទូលទៅកាន់ទ្រង់វិញ
ក) តាមរយៈការយល់សប្ដិ និង និមិត្ត។
ខ) តាមរយៈការអធិស្ឋាន
គ) តាមរយៈភាពស្ងៀមស្ងាត់
ឃ) យ៉ាងឮៗ។

១២ សម្រាប់បញ្ហាសាមញ្ញៗភាគច្រើន មធ្យោបាយដើម្បីដោះស្រាយបញ្ហាដែលយើងត្រូវការគឺ

ក) ការអធិស្ឋាន និង ការតបអាហារយ៉ាងម៉ត់ចត់

ខ) សុភនិច្ឆ័យ និង ហេតុផល។

គ) ព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធទាំងអស់។

ឃ) ព្រះបន្ទូលដែលប្រកបដោយប្រាជ្ញារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

១៣ ដើម្បីគ្រប់គ្រងអាកប្បកិរិយារបស់អ្នក ដំបូងបំផុតអ្នកត្រូវគ្រប់គ្រងគំនិតរបស់អ្នក និង

ក) គំនិតរវើរវាយរបស់អ្នក។

ខ) អារម្មណ៍របស់អ្នក

គ) សំដីរបស់អ្នក។

ឃ) ចិត្តរបស់អ្នក។

១៤ ការដោះស្រាយបញ្ហាតាមរបៀបដូចជាព្រះគ្រិស្ត ទាមទារឲ្យយើង

ក) ស្ម័គ្រចិត្តបដិសេធថាគ្មានបញ្ហានោះទេ។

ខ) ត្រៀមខាងឯវិញ្ញាណ គ្រប់ពេលវេលា។

គ) ឯករាជ្យ និង ចរចេសរឹងរូស

ឃ) ត្រូវបានធ្វើឲ្យល្អឥតខ្ចោះដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

១៥ ចូរអានគម្ពីររ៉ូម ១២:១៩។ នៅពេលដែលយើងត្រូវគេបំពាន ជំនួសឲ្យការខឹង យើងគួរតែ

ក) ថ្វាយបញ្ហានោះទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ហើយទុកឲ្យទ្រង់ឆ្លើយតបជំនួសយើងវិញ។

ខ) អធិស្ឋានសុំឲ្យមានការសងសឹក លើមនុស្សដែលបានធ្វើខុសចំពោះយើង។

គ) រៀបចំផែនការឲ្យបានម៉ត់ចត់ដើម្បី ធ្វើការសងសឹកដ៏យុត្តិធម៌មួយ។

ឃ) អួតប្រាប់គេអំពីផែនការសងសឹករបស់យើង។

១៦ ការរត់គេចពីបញ្ហាគឺ

ក) តែងតែជាអំពើកំសាក និង មិនត្រឹមត្រូវនោះទេ។

ខ) ហៅថាការដកថយ ឬ ការដកខ្លួនចេញ។

គ) តែងតែជាចម្លើយដែលបានមកពីក្នុងព្រះគម្ពីរ។

ឃ) ហៅថាការបដិសេធ ឬ ការប្រកែក។

១៧ ការធ្វើអ្វីមួយដើម្បីធ្វើបាបអ្នកដែលបានធ្វើបាបអ្នកគឺហៅថា

ក) ការសងសឹក

ខ) ការដកខ្លួនចេញ

គ) ការចោទប្រកាន់

ឃ) គ្មានមនសិការ

១៨ ទាក់ទងនឹងការដោះស្រាយបញ្ហារបស់គ្រិស្តបរិស័ទ អំណាចឆន្ទៈរបស់មនុស្សគឺ

ក) ជាការដោះស្រាយដែលមិនត្រឹមត្រូវ

ខ) ពេលខ្លះមានប្រយោជន៍ នៅពេលមានការអធិស្ឋានរួមជាមួយដែរ។

គ) មធ្យោបាយដ៏ល្អបំផុតសម្រាប់គ្រិស្តបរិស័ទដោះស្រាយបញ្ហា។

ឃ) ជាមធ្យោបាយតែមួយគត់ដែលចាំបាច់ក្នុងការដោះស្រាយបញ្ហាភាគច្រើន។

១៩ ជំហានដំបូងនៅក្នុងការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធគឺត្រូវ

ក) ស្គាល់បញ្ហាឲ្យបានច្បាស់បំផុតតាមតែអាចធ្វើទៅបាន។

ខ) ថ្វាយបញ្ហាទៅកាន់ព្រះជាម្ចាស់។

គ) ពិចារណាដំណោះស្រាយទាំងអស់ដែលអាចមាន។

ឃ) លះបង់ចោលការស្វែងរកដំណោះស្រាយ។

២០ ចូរអានគម្ពីរ១ពេត្រុស ៥:៧ ។ តើជំហានទីពីរ នៅក្នុងការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធគឺអ្វី?

ក) គិតប្រកបដោយភាពច្នៃប្រឌិត។

ខ) គិតពីដំណោះស្រាយដែលអាចទៅរួច។

គ) ថ្វាយបញ្ហាទៅកាន់ព្រះអម្ចាស់។

ឃ) ទទួលស្គាល់ថាគ្មានដំណោះស្រាយសម្រាប់បញ្ហានោះទេ។

# ការប្រឡងជំពូកទីពីរ

១ បញ្ហាដ៏ធំមួយនៅក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃគឺភាពលោភលន់ ឬអាចហៅថា

ក) ការផ្ដល់ប្រាក់

ខ) ទ្រឹស្ដីសេដ្ឋកិច្ច

គ) សេចក្ដីលោភ

ឃ) ការសន្សំសំចៃ

២ យើងអាចបកស្រាយភាពលោភលន់បានល្អបំផុត ថាជា

ក) ការចង់បានអ្វីដែលអ្នកដទៃមាន។

ខ) ការប្រៀបធៀបខ្លួនអ្នកទៅជាមួយនឹងអ្នកដទៃ។

គ) ការព្យាយាមដើម្បីឲ្យអស់ពីសមត្ថភាពរបស់អ្នក។

ឃ) អំពើផឹកក្បត់នៅក្នុងអាពាហ៍ពិពាហ៍

៣ យោងទៅតាមគម្ពីរលូកា ២២:២៥-២៦ បញ្ហាដែលកើតមកពីការស្វែងរកឋានៈអាចដោះស្រាយបានដោយ

ក) ឥរិយាបថនៃក្ដីស្រឡាញ់ និង ការបម្រើអ្នកដទៃ។

ខ) ការបូជាខ្លួនឯង និង ការរងទុក្ខ។

គ) ឲ្យអ្វីៗទាំងអស់ដែលយើងមានទៅដល់អ្នកក្រីក្រ។

ឃ) ធ្វើជាឥសីកាន់សីល។

៤ ការយកឈ្នះលើអារម្មណ៍ដែលធ្វើឲ្យយើង និង អ្នកដទៃឈឺចាប់ នៅក្នុងទំនាក់ទំនង គឺជាបញ្ហា នៃ

ក) លែងខ្វល់ពីអារម្មណ៍របស់អ្នកដទៃ។

ខ) ភាពពេញវ័យរបស់គ្រិស្ដបរិស័ទ ដែលកើតមាននៅក្នុងពេលណាមួយ។

គ) អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធរំដោះយើងឲ្យផុតពីអំពើបាប។

ឃ) រៀនច្រានចោលអារម្មណ៍ និង ភាពទន់ខ្សោយ។

៥ តួនាទីនៃអំណាចឆន្ទៈរបស់មនុស្សនៅក្នុងភាពពេញវ័យរបស់គ្រិស្ដបរិស័ទគឺ

ក) ធ្វើឲ្យយើងអសមត្ថភាពក្នុងការប្រព្រឹត្តអំពើបាប។

ខ) ធ្វើការសម្រេចចិត្តស្ដាប់បង្គាប់ព្រះជាម្ចាស់។

គ) ធ្វើឲ្យគំនិតរបស់យើងមានអំណាច

ឃ) ធ្វើឲ្យយើងវេទនា

៦ ទោះបីមាន ឬក្រ យើងត្រូវចាំថា យើងគឺ

ក) ជាអ្នកគ្រប់គ្រងប្រាក់ដែលព្រះជាម្ចាស់ប្រទានមកឲ្យយើង។

ខ) ត្រូវបានចាត់តាំងឲ្យទទួលបានទ្រព្យសម្បត្តិលើលោកីយ៍។

គ) ត្រូវលះបង់ទ្រព្យសម្បត្តិទាំងអស់ដើម្បីព្រះគ្រិស្ដ។

ឃ) ត្រូវថ្វាយ១០ភាគរយប៉ុណ្ណោះទៅព្រះជាម្ចាស់។

៧ ចូរអានគម្ពីររ៉ូម ១២:១៧-២១។ តើយើងត្រូវឆ្លើយតបយ៉ាងដូចម្ដេចនៅពេលដែលយើងទទួលរងភាពអយុត្តិធម៌?

ក) ជាមួយក្ដីស្រឡាញ់

ខ) ជាមួយភាពម្ហូរម៉ៅ

គ) ជាមួយភាពល្ងីងល្ងរចត់

ឃ) ជាមួយការគំនុំសងសឹក

៨ បញ្ហានៅក្នុងចំណងអាពាហ៍ពិពាហ៍ និង ក្នុងគ្រួសារជាច្រើនអាចនឹងមិនកើតមានឡើងទេ ប្រសិនបើគ្រិស្តបរិស័ទ

ក) មិនរៀបការជាមួយសមាជិកនៅក្នុងក្រុមជំនុំផ្សេង។

ខ) រៀបការ ជាមួយអ្នកមិនជឿ ហើយផ្លាស់ប្រែពួកគេ។

គ) គ្រប់គ្នាជ្រើសរើសនៅលីវ។

ឃ) មិនរៀបការជាមួយនឹងអ្នកមិនជឿ។

៩ ប្រសិនបើអ្នកជឿ និង អ្នកមិនជឿរៀបការជាមួយគ្នា អ្នកជឿមានទំនួលខុសត្រូវក្នុងការ

ក) ស្វែងរកការលែងលះភ្លាមៗ។

ខ) បង្ខិតបង្ខំគ្រួសារឲ្យទៅព្រះវិហារ។

គ) បង្ខំឲ្យដៃគូដែលជាអ្នកមិនជឿ ទទួលយកព្រះគ្រិស្ត។

ឃ) ធ្វើអ្វីៗដែលគាត់អាចធ្វើបានដើម្បីឲ្យអាពាហ៍ពិពាហ៍អាចដំណើរការទៅមុខបាន។

១០ គម្ពីរ១កូរិនថូស ៧:៥ បង្រៀនថា ការរួមភេទ និង ការតមនៅជាមួយគ្នា ក្នុងជីវិតប្ដីប្រពន្ធត្រូវសម្រេចដោយ

ក) ចំណង់របស់ប្ដី

ខ) ការព្រមព្រៀងគ្នាទៅវិញទៅមក

គ) ចំណង់របស់ប្រពន្ធ

ឃ) ការបង្កើតកូនចៅ

១១ ចូរអានគម្ពីរម៉ាថាយ ១៩:៩ ។ តើព្រះយេស៊ូមានព្រះបន្ទូលថា ការលែងលះគ្នាអាចធ្វើទៅបាននៅពេលណា?

ក) គ្រិស្តបរិស័ទមិនត្រូវបានអនុញ្ញាតឲ្យធ្វើការលែងលះគ្នាឡើយ។

ខ) គ្រិស្តបរិស័ទអាចលែងលះគ្នាបានតែនៅពេលមានវិបត្តិហិរញ្ញវត្ថុតែប៉ុណ្ណោះ។

គ) គ្រិស្តបរិស័ទត្រូវបានអនុញ្ញាតឲ្យលែងលះគ្នាបាន តែនៅពេលមានភាពសហាយស្មន់តែប៉ុណ្ណោះ។

ឃ) គ្រិស្តបរិស័ទ ត្រូវបានអនុញ្ញាតឲ្យលែងលះគ្នា ប្រសិនបើពួកគេ " ឈប់ស្រឡាញ់គ្នាហើយ"

១២ ការប្រច័ណ្ឌគឺតែងតែបណ្ដាលមកពីខ្វះ

ក) ការគោរព និង ការទុកចិត្តគ្នា។

ខ) ការណែនាំរឿងផ្លូវភេទ។

គ) ធនធានហិរញ្ញវត្ថុ។

ឃ) ឱកាស។

១៣ ការបណ្ដុះបណ្ដាលកូនត្រឹមត្រូវគឺរួមមាន

ក) ការបង្រៀន ការប្រៀនប្រដៅ និង ការស្រឡាញ់។

ខ) ការដាក់ទោស និង ការសរសើរ។

គ) ការលើកទឹកចិត្តជាលុយ។

ឃ) ភាពបណ្ដែតបណ្ដោយ។

១៤ ទំនួលខុសត្រូវ ទាំងបីរបស់ប្ដីដែលនៅក្នុងព្រះគម្ពីរនៅក្នុងគ្រួសារ គឺ ផ្ដល់ការដឹកនាំ ការផ្គត់ផ្គង់ និង

ក) ប្រៀនប្រដៅប្រពន្ធ និង កូនៗរបស់គាត់។

ខ) ឲ្យកាដូថ្លៃៗទៅដល់គ្រួសាររបស់គាត់។

គ) តាមដានសកម្មភាពប្រពន្ធរបស់គាត់យ៉ាងយកចិត្តទុកដាក់។

ឃ) ស្រឡាញ់ប្រពន្ធរបស់គាត់ដូចជាព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំដែរ។

១៥ អ្នកនៅលីវនៅក្នុងសង្គមរបស់យើង ចែកជាបីប្រភេទ៖ អ្នកដែលមិនធ្លាប់រៀបការ

ក) អ្នកដែលលែងលះគ្នា និង អ្នកដែលជាពោះម៉ាយ ឬមេម៉ាយ

ខ) អ្នកដែលមិនធ្លាប់រៀបការ និង អ្នកដែលមិនខ្វល់ខ្វាយ

គ) អ្នកដែលលែងលះគ្នា និង អ្នកដែលចែកផ្លូវគ្នាស្របច្បាប់

ឃ) អ្នកដែលមិនចង់រៀបការ និង អ្នកដែលរស់នៅជាមួយគ្នាទាំងនៅលីវ

១៦ លោកប៉ូលបានមានប្រសាសន៍នៅក្នុងគម្ពីរ១កូរិនថូសជំពូក៧ ថាគុណប្រយោជន៍មួយនៃភាពនៅលីវ គឺសេរីភាព

ក) ដើម្បីរស់នៅក្នុងជីវិតក៏អាថ៌កំបាំងមួយ។

ខ) ដើម្បីសកម្មខាងរឿងផ្លូវភេទ។

គ) ផុតពីសម្ពាធរបស់គ្រួសារ។

ឃ) ផុតពីទំនួលខុសត្រូវទាំងអស់។

១៧ ក្នុងចំណោមអំណោយទានពិសេសរបស់ព្រះជាម្ចាស់ទៅកាន់ក្រុមជំនុំ គឺមានអ្នកនៅលីវដែលសុខចិត្តលះបង់ការរៀបការ ដើម្បី

ក) រស់នៅក្នុងភាពក្រីក្រ និង ការមួម៉ៅក្នុងចិត្ត។

ខ) បង្រៀនថ្នាក់អ្នកលីវនៅថ្ងៃអាទិត្យ។

គ) ថ្វាយជីវិតពួកគេសម្រាប់កិច្ចការរបស់ព្រះជាម្ចាស់។

ឃ) ប្រមូលយកទ្រព្យ និង អំណាចផ្ទាល់ខ្លួន។

១៨ អ្នកដែលចង់រៀបការខ្លាំង ប៉ុន្តែមិនអាចរៀបការជាមួយគ្រិស្តបរិស័ទបានគួរតែ

ក) រៀបការជាមួយអ្នកមិនជឿ។

ខ) លះបង់ចោលជម្រើសរៀបការ។

គ) បន្តនៅលីវ ប៉ុន្តែមិនចាំបាច់មានភាពបរិសុទ្ធទេ។

ឃ) បន្តនៅមានភាពបរិសុទ្ធ(នៅលីវ) និង ទុកចិត្តលើព្រះជាម្ចាស់។

១៩ មធ្យោបាយមួយដើម្បីបំបាត់ភាពឯកា និង ការស្រណោះខ្លួន គឺត្រូវ

ក) ប្រាប់នរណាម្នាក់អំពីវា។

ខ) នៅក្បែរមនុស្សម្នា។

គ) ជួយអ្នកដទៃដែលមានតម្រូវការខ្លាំងជាងយើង។

ឃ) សម្រេចចិត្តថា នឹងនៅឯកាជារៀងរហូត។

២០ ក្រុមជំនុំជាច្រើនជួយអ្នកនៅលីវដោះស្រាយបញ្ហារបស់ពួកគេតាមរយៈ

ក) គ្រួសារដែល "ទទួលយក" អ្នកនៅលីវដើម្បីផ្តល់មិត្តភាពឲ្យគេ។

ខ) រៀបចំកម្មវិធី "ដេញថ្លៃ" ចាប់គូសម្រាប់អ្នកនៅលីវ។

គ) ឈ្មោះដែលគួរឲ្យចាប់អារម្មណ៍សម្រាប់អ្នកនៅលីវ ដូចជា "អ្នកមានគូ និង អ្នកនៅសល់"

ឃ) កាត់បន្ថយការចូលរួមនៅក្នុងក្រុមជំនុំរបស់ពួកគេ ឲ្យនៅក្នុងក្រុមសម្រាប់អ្នកនៅលីវសុទ្ធតែប៉ុណ្ណោះ។

# ការប្រឡងជំពូកទីបី

១ នៅក្នុងរឿងជីវិតផ្លូវភេទ ជម្រើសដែលមាននៅក្នុងព្រះគម្ពីរតែមួយគត់ក្នុងការរៀបអាពាហ៍ពិពាហ៍ គឺ

ក) ភាពបរិសុទ្ធ

ខ) ការរួមមកតែមួយ

គ) ការបង្កើតកូនចៅ

ឃ) រួមភេទមុនរៀបការ

២ ការណែនាំសម្រាប់រឿងផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍អាចសរុបមកជាពាក្យថា

ក) ការបង្កើតកូនចៅ

ខ) ការផ្លាស់ប្ដូរ

គ) ការអត់ទោស

ឃ) ការពឹងពាក់គ្នាទៅវិញទៅមក

៣ ទំនាក់ទំនងផ្លូវភេទជាធម្មតា នៅក្នុងចំណងអាពាហ៍ពិពាហ៍គឺដើម្បី

ក) ធ្វើជាការធានាសុវត្ថិភាពឲ្យចំណងអាពាហ៍ពិពាហ៍នោះ។

ខ) បង្វែរយើងមិនឲ្យបម្រើព្រះជាម្ចាស់។

គ) បង្កើតជម្លោះ

ឃ) បង្ហាញពីភាពខ្វះខាតជំនឿ

៤ យោងទៅតាមគម្ពីររ៉ូម ១:២៤-២៨ ការរួមសង្វាសភេទដូចគ្នា គឺ

ក) ជាអំពើបាប។

ខ) ជាជម្រើសមួយនៅក្នុងការរស់នៅ។

គ) ជារឿងធម្មតាបំផុតសម្រាប់អ្នកខ្លះ។

ឃ) អ្វីម្យ៉ាងដែលគ្មាននរណាម្នាក់យល់នោះទេ។

៥ បញ្ហាខាងឯផ្លូវភេទ ដែលជាលទ្ធផលនៃអំពើបាបអាចដោះស្រាយបានតាមរយៈ

ក) ការប្រឹក្សាយោបល់ និង ការព្យាបាលដោយឱសថ។

ខ) បំភ្លេចវាចោល តែមិនអត់ទោសឲ្យនោះ។

គ) ការលន់តួ និង ការអត់ទោស។

ឃ) ឱសថ និង ការវះកាត់

៦ ភាពខុសគ្នាដ៏ចម្បងបំផុត រវាងការបាក់ទឹកចិត្ត និង ភាពក្រៀមក្រំធម្មតាគឺថា

ក) ភាពក្រៀមក្រំ មិនមែនជាផ្នែកមួយនៃការបាក់ទឹកចិត្តនោះទេ។

ខ) ការបាក់ទឹកចិត្តទាមទារការព្យាបាលដោយឱសថ

គ) ភាពក្រៀមក្រំធម្មតា នឹងបាត់ទៅវិញឆាប់ៗ

ឃ) ការបាក់ទឹកចិត្ត នឹងបាត់ទៅវិញឆាប់ៗ

៧ ជំងឺខាងរូបកាយ និង ការបាក់ទឹកចិត្តគឺ

ក) តែងតែទាក់ទងគ្នា។

ខ) មិនទាក់ទងគ្នានោះទេ។

គ) ទាំងពីរបណ្តាលមកពីអំពើបាប។

ឃ) បណ្តាលមកពីការខ្វះជំនឿ។

៨ ចូរអានគម្ពីរ១យ៉ូហាន៤:១៦-១៨ ។ តើថ្នាំបន្សាបរបស់ព្រះជាម្ចាស់សម្រាប់ភាពភ័យខ្លាចជាអ្វី?

ក) អំណាចឆន្ទៈរបស់មនុស្ស

ខ) សេចក្តីស្រឡាញ់របស់ទ្រង់។

គ) សុទិដ្ឋិនិយម

ឃ) ការសង្ស័យ

៩ ទោសកំហុស មិនថាមកពីអំពើបាប ឬ ការស្តាយក្រោយក៏ដោយ គឺសុទ្ធតែអាចយកចេញបាន នៅពេលដែលយើងទទួល

ក) ការណែនាំ។

ខ) ការដាក់ទោស។

គ) ការអត់ទោស។

ឃ) ការបាក់ទឹកចិត្ត។

១០ មធ្យោបាយដ៏ល្អបំផុតមួយដើម្បីជួយអ្នកដែលមានការបាក់ទឹកចិត្តគឺត្រូវ

ក) មានវត្តមាននៅក្បែរ និង ផ្តល់ក្តីស្រឡាញ់។

ខ) ប្រាប់ថាពួកគេត្រូវលន់តួ។

គ) អធិស្ឋានដើម្បីឲ្យព្រះជាម្ចាស់អត់ទោសឲ្យពួកគេ។

ឃ) ផ្តន្ទាទោសការខ្វះខាតជំនឿរបស់ពួកគេ។

១១ មូលហេតុមួយដែលការឈឺចាប់អាចជាព្រះពរ គឺថា

ក) វាអាចបំផ្លាញយើងទាំងខាងផ្លូវចិត្ត និង ខាងរូបកាយ។

ខ) វាអាចរំឭកយើងថាមានបញ្ហាដែលត្រូវដោះស្រាយ។

គ) វាគឺជារឿងទូទៅ ជាស្ថានភាពមួយដែលមិនអាចជៀសបាន ។

ឃ) វាធ្វើឲ្យមិត្តភក្តិ និងគ្រួសាររបស់យើងអាណិតអាសូរយើង។

១២ ចូរអានគម្ពីរយ៉ូប ១:២១-២២ ។ តើឥរិយាបថរបស់លោកយ៉ូបទៅចំពោះទុក្ខព្រួយ និង ការបាត់បង់?

ក) លោកបដិសេធមិនទទួលស្គាល់អ្វីដែលកើតមានឡើងចំពោះលោកនោះទេ។

ខ) លោកមានភាពល្វីងជូរចត់ និង ថ្នាំងថ្នាក់ទៅចំពោះព្រះជាម្ចាស់។

គ) លោកនៅតែបន្តថ្វាយបង្គំព្រះជាម្ចាស់ប្រកបដោយជំនឿ។

ឃ) លោកលែងទទួលស្គាល់ព្រះជាម្ចាស់ ហើយបាត់បង់គ្រួសាររបស់លោក។

១៣ គ្រិស្តបរិស័ទអាចនឹងឆ្លងកាត់ដំណាក់កាលទី១ គឺការបដិសេធចំពោះការស្លាប់ ព្រោះគំនិតដែលទាក់ទងនឹងការស្លាប់

ក) គួរឲ្យភ័យខ្លាចណាស់ ទោះបីចំពោះគ្រិស្តបរិស័ទក៏ដោយ។

ខ) គឺមិនអាចទទួលយកបាននោះទេ ព្រោះអ្នកជឿទាំងអស់ គឺសុទ្ធតែមានជីវិតអស់កល្បហើយនៅពេលនេះ។

គ) កាត់បន្ថយអ្វីដែលគេជឿថាជាផែនការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគេ។

ឃ) ហាក់បីដូចជាផ្ទុយពីការយល់របស់ពួកគេដែលថា ព្រះគ្រិស្តបានប្រទានការប្រោសឲ្យជារួចស្រេចហើយ។

១៤ ពេលវេលាដ៏ល្អបំផុតដើម្បីពិភាក្សាអំពីបញ្ហាជាក់ស្តែង និង បញ្ហាគ្រួសារ ទាក់ទងទៅនឹងការស្លាប់នោះគឺ

ក) នៅក្នុងដំណាក់កាល "តថ្លៃ" ចំពោះការស្លាប់។

ខ) នៅពេលដែលអ្នកមានអាយុ៧០ឆ្នាំភ្លាម។

គ) នៅពេលដែលអ្នកនៅមានសុខភាពល្អ។

ឃ) មិនត្រូវឆាប់ពេកនោះទេ។

១៥ បញ្ហាដ៏ធំបំផុតសម្រាប់អ្នកដែលដឹងខ្លួនថាពួកគេកំពុងតែជិតស្លាប់គឺ

ក) ការសុំការអត់ទោសចំពោះអ្វីដែលពួកគេបានធ្វើ។

ខ) ការរៀបចំកិច្ចការហិរញ្ញវត្ថុរបស់ពួកគេឲ្យបានត្រឹមត្រូវ។

គ) ការធ្វើបណ្ដាំផ្សេងៗ

ឃ) រៀបចំខ្លួនដើម្បីចូលគាល់ព្រះជាម្ចាស់។

១៦ យោងទៅតាមគម្ពីរហេប្រឺ ១២:២-៣ ព្រះគ្រិស្តរងទុក្ខ និង សុគតដើម្បី

ក) ជាការជំរុញចិត្តយើងឲ្យបរិភោគអាហារធ្វើឲ្យមានសុខភាពល្អ។

ខ) ប្រាប់យើងថាការស្លាប់នឹងជាការលំបាក។

គ) រំដោះយើងពីទុក្ខព្រួយទាំងអស់។

ឃ) លើកទឹកចិត្តយើង។

១៧ ការយកចិត្តទុកដាក់តែលើព្រះពរ និងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ជាជាងបារម្ភពីបញ្ហា គឺហៅថា

ក) ភាពឆោតល្ងង់

ខ) ការជឿជាក់

គ) ការអះអាងបញ្ជាក់

ឃ) ការលន់តួ

១៨ គម្ពីររ៉ូម ៤:២១ បង្រៀនយើងថា ព្រះជាម្ចាស់មានឫទ្ធានុភាពដើម្បីធ្វើ

ក) អ្វីដែលអធិស្ឋានបង្ខំឲ្យទ្រង់ធ្វើ។

ខ) អ្វីដែលយើងអនុញ្ញាតឲ្យទ្រង់ធ្វើប៉ុណ្ណោះ។

គ) អ្វីដែលទ្រង់បានសន្យាថានឹងធ្វើ។

ឃ) អ្វីដែលយើងបង្ខំឲ្យទ្រង់ធ្វើ។

១៩ ការអះអាងបញ្ជាក់នៅក្នុងព្រះគម្ពីរ គឺផ្អែកលើអ្វីដែលព្រះជាម្ចាស់បានធ្វើរួច និង ជំនឿរបស់យើង ដែលថា

ក) យើងស័ក្តិសមទទួលជំនួយពីទ្រង់។

ខ) យើងអាចបញ្ចុះបញ្ចូលទ្រង់ឲ្យថែរក្សាយើងបាន។

គ) ទ្រង់នឹងបន្តសកម្មភាពរបស់ទ្រង់នៅក្នុងពេលអនាគតទៀត។

ឃ) ទ្រង់នឹងមិនប្រទានព្រះពររបស់ទ្រង់មកយើងនៅពេលអនាគតទេ។

២០ គម្ពីរហេប្រឺជំពូក១១ បង្រៀនយើងថា មានចំណងយ៉ាងមាំរវាងជំនឿរបស់យើង និង

ក) ក្តីសង្ឃឹមរបស់យើង

ខ) កំហឹងរបស់យើង

គ) ការអស់សង្ឃឹមរបស់យើង

ឃ) ចំណង់ចិត្តរបស់យើង។